| ការប្តូរចំណេញរក្សាទុកទៅដើមទុន | ១២.០០០.០០០ | ៤៨.៨៨៨.០០០ | - | - | (១២.០០០.០០០) | (៤៨.៨៨៨.០០០) | - | - | - |
| ការផ្ទេរពីចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | ១៧.៨៧២.០៩២ | ៧២.៨១០.៩០៣ | (១៧.៨៧២.០៩២) | (៧២.៨១០.៩០៣) | - | - | - |
| ភាគលាភបានបង់ | - | - | - | - | (១.៥០០.០០០) | (៦.១១១.០០០) | - | (១.៥០០.០០០) | (៦.១១១.០០០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៥.១៣០.០០០ | - | - | - | - | (៦៧.៥០០) | - | ៥.០៦២.៥០០ |
| **ប្រតិបត្តិការសរុបជាមួយម្ចាស់ភាគទុនិកៈ** | ១២.០០០.០០០ | ៥៤.០១៨.០០០ | ១៧.៨៧២.០៩២ | ៧២.៨១០.៩០៣ | (៣១.៣៧២.០៩២) | (១២៧.៨០៩.៩០៣) | (៦៧.៥០០) | (១.៥០០.០០០) | (១.០៤៨.៥០០) |
| **សមតុល្យនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | ១១៤.០០០.០០០ | ៤៦៩.៥៦៦.០០០ | ៣២.៧៨៣.៨១០ | ១៣៥.១២៣.៣០៤ | ៤២.៦២១.៩១៤ | ១៧២.១០៦.១៥៥ | ៣.៣៦៦.៧១៨ | ១៨៩.៤០៥.៧២៤ | ៧៨០.១៦២.១៧៧ |

## របាយការណ៍បម្រែបម្រួលមូលធនដោយឡែកសង្ខេប
## សម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣

| | ដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | ១១៤.០០០.០០០ | ៤៦៩.៣៣៨.០០០ | ៣៦.១០៦.០០២ | ១៤៨.៩៣៣.៤៤០ | ៤៤.១៨៥.២៧៨ | ១៧៨.៣២៣.៣១៤ | ៣.៣០២.៤៤៦ | ១៩៤.២៩១.២៨០ | ៧៩៩.៨៩៧.២០០ |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | - | - | ១៩.៤៤២.២៨០ | ៧៩.៨៤៩.៤៤៣ | - | ១៩.៤៤២.២៨០ | ៧៩.៨៤៩.៤៤៣ |
| លទ្ធផលលម្អិតផ្សេងៗ - លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | ៧៨៥.២៧៤ | - | ៧៨៥.២៧៤ |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | - | - | - | - | ១៩.៤៤២.២៨០ | ៧៩.៨៤៩.៤៤៣ | ៧៨៥.២៧៤ | ១៩.៤៤២.២៨០ | ៨០.៦៣៤.៧១៧ |
| **ប្រតិបត្តិការជាមួយម្ចាស់សម្ព័ន្ធធនាគារក្នុងនាមជាភាគទុនិកះ** | | | | | | | | | |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិទៅចំណេញរក្សាទុក | - | - | (១.១៧៨.៨៥៣) | (៤.៨៤១.៥៤៩) | ១.១៧៨.៨៥៣ | ៤.៨៤១.៥៤៩ | - | - | - |
| ភាគលាភបានបង់ | - | - | - | - | (២.០០០.០០០) | (៨.២១៤.០០០) | - | (២.០០០.០០០) | (៨.២១៤.០០០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៥៧០.០០០ | - | (១២២.១៨៣) | - | - | - | - | ៤៤៧.៨១៧ |
| **ប្រតិបត្តិការសរុបជាមួយម្ចាស់ភាគទុនិកះ** | - | ៥៧០.០០០ | (១.១៧៨.៨៥៣) | (៤.៩៦៣.៧៣២) | (៨២១.១៤៧) | (៣.៣៧២.៤៥១) | - | (២.០០០.០០០) | (៧.៧៦៦.១៨៣) |
| **សមតុល្យនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣** | ១១៤.០០០.០០០ | ៤៦៩.៩០៨.០០០ | ៣៤.៩២៧.១៤៩ | ១៤៣.៩៦៩.៧០៨ | ៦២.៨០៦.៤១១ | ២៥៤.៨០០.៣០៦ | ៤.០៨៧.៧២០ | ២១១.៧៣៣.៥៦០ | ៨៧២.៧៦៥.៧៣៤ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី ១៨ ដល់ទំព័រទី ២៦ គឺជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុចន្លោះពេលដោយឡែកសង្ខេបនេះ។

**ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក**

## របាយការណ៍លំហូរសាច់ប្រាក់ដោយឡែកសង្ខេប
## សម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ ៩ខែ | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | ២៤.៦០៨.៤៦១ | ១០១.០៦៦.៩៤៨ | ២២.៦៦៥.៩២៩ | ៩២.៣៤០.៩៩៦ |
| *និយ័តកម្ម៖* | | | | |
| សំវិធានធនសម្រាប់កាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិក | ៤២.៣៤៧ | ១៧៣.៩១៩ | ៥៦.១១៩ | ២២៨.៦២៩ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | ៥.០៤៩.៤៩៩ | ២០.៧៣៨.២៩២ | ៥.៤៧៨.១៨៤ | ២២.៣១៨.១២១ |
| ខាតពីឱនភាពតម្លៃចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ | ២.៨៨៩.៤៨៤ | ១១.៨៦៧.១១១ | ១.៣០៤.៨៩៤ | ៥.៣១៦.១៣៨ |
| ចំណេញពីការប្តូររូបិយប័ណ្ណមិនទាន់ទទួលស្គាល់លើមូលបត្រវិនិយោគ | (១.៩០២) | (៧.៨១២) | (២៦.៥០៨) | (១០៧.៩៩៤) |
| ខាតពីការប្តូររូបិយប័ណ្ណមិនទាន់ទទួលស្គាល់លើប្រាក់កម្ចី និងមូលបត្របំណុល | ១៩៣.៥៩៦ | ៧៩៥.០៩៩ | ៤៧.០០៣ | ១៩១.៤៩១ |
| ចំណូលការប្រាក់ | (៦៧.៨០២.៩១១) | (២៧៨.៤៦៦.៥៥៥) | (៥៧.០០២.៤៩៧) | (២៣២.២២៨.១៧៣) |
| ចំណាយការប្រាក់ | ២៦.៥៦៥.១៨០ | ១០៩.១០៣.១៩៤ | ១៨.៤០១.៥០០ | ៧៤.៩៦៧.៧១១ |
| | | | | |
| *បម្រែបម្រួលដើមទុនបង្វិល៖* | | | | |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | (១០.៣៧០.៩៣៨) | (៤២.៥៩៣.៤៤២) | ១៦.៤០៥.៦៧៩ | ៦៦.៨៣៦.៧៣៦ |
| សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ៣.០០០.០០០ | ១២.៣២១.០០០ | ៨.០១៩.១៥២ | ៣២.៦៧០.០២៥ |
| ឥណទានផ្តល់ដល់អតិថិជន | (៦៤.៦៥០.០០៤) | (២៦៥.៥១៧.៥៦៦) | (៤០.១១២.៣៦២) | (១៦៣.៤១៧.៧៦៣) |
| ទ្រព្យសកម្មផ្សេងៗ | (១.៣៩១.១០២) | (៥.៧១៣.២៥៦) | (១.២៧១.៨០២) | (៥.១៨១.៣២១) |
| ប្រាក់បញ្ញើពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ២៤.៥២៨.៦០៣ | ១០០.៧៣៨.៩៧៣ | ១០៣.៨៨១.៧៣៥ | ៤២៣.២១៤.១៨៨ |
| ប្រាក់បញ្ញើពីអតិថិជន | ៣០.៧១៤.៩៦៦ | ១២៦.១៩៦.៣៦៥ | (១១៣.៦៨៣.៦៥៥) | (៤៦៣.១៩៧.២១០) |
| បំណុលផ្សេងៗ | ៤៣៨.៥២១ | ១.៨០១.០០៦ | ១៨៤.៧០៨ | ៧៥២.៥០០ |
| សាច់ប្រាក់ប្រើក្នុងប្រតិបត្តិការ | (២៦.១៨៦.២០០) | (១០៧.៥៤៦.៧២៤) | (៣៥.៦៥១.៩២១) | (១៤៥.២៤៥.៩២៦) |
| | | | | |
| ការប្រាក់បានទទួល | ៦៣.៣៣១.៩២៥ | ២៦០.១០៤.២១៦ | ៥៨.៩៩៨.៧៧០ | ២៣៨.៣២៣.៩៨៩ |
| ការប្រាក់បានបង់ | (២១.១៣៨.៦៨៤) | (៨៦.៨១៦.៥៧៥) | (១៩.៤៥៩.៤០៣) | (៧៩.២៧៧.៦០៨) |
| ពន្ធលើប្រាក់ចំណូលបានបង់ | (១.៨៨៧.៣៦៤) | (៧.៧៥១.៤០៤) | (៣.៩៥៩.៩៥២) | (១៦.១៣២.៨៤៤) |
| **សាច់ប្រាក់សុទ្ធពី/ (ប្រើក្នុង)សកម្មភាពប្រតិបត្តិការ** | ១៤.១១៩.៦៧៧ | ៥៧.៩៨៩.៥១៣ | (៥៧២.៥០៦) | (២.៣៣២.៣៨៩) |
| | | | | |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | (៥២៦.២៩៦) | (២.១៦១.៤៩៨) | (៨៤០.៩៨៣) | (៣.៤២៦.១៦៥) |
| ការទិញទ្រព្យសកម្មអរូបី | (១៤២.២១១) | (៥៨៤.០៦១) | (៣១៤.៨៩០) | (១.២៨២.៨៦២) |
| សាច់ប្រាក់បានពីមូលបត្រវិនិយោគ | - | - | ២.៩៤៧.៣១៧ | ១២.០០៧.៣៦៩ |
| **សាច់ប្រាក់សុទ្ធ(ប្រើក្នុង)/បានពីសកម្មភាពវិនិយោគ** | (៦៦៨.៥០៧) | (២.៧៤៥.៥៥៩) | ១.៧៩១.៤៤៤ | ៧.២៩៨.៣៤២ |

## របាយការណ៍លំហូរសាច់ប្រាក់ដោយឡែកសង្ខេប
## សម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ ៩ខែ | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| ភាគលាភបានបង់ | (២.០០០.០០០) | (៨.២១៤.០០០) | (១.៥០០.០០០) | (៦.១១១.០០០) |
| សាច់ប្រាក់បានពីប្រាក់កម្ចី | ១០.០០០.០០០ | ៤១.០៧០.០០០ | ១.៣២៦.៥០០ | ៥.៤០៤.១៦១ |
| ការទូទាត់សងប្រាក់កម្ចី | (៣៨៨.០៩៥) | (១.៥៩៣.៨០២) | (៧.៥៥៧.៨៧៦) | (៣០.៧៩០.៧៨៧) |
| ការទូទាត់សងមូលបត្របំណុល | (១៩.៥៦៩.៩៨១) | (៨០.៣៧៣.៩១២) | - | - |
| ការបង់ប្រាក់ដើមនៃភតិសន្យា | (១.៩៦៩.១៨៧) | (៨.០៨៧.៤៥១) | (១.៩៥៦.៥៥២) | (៧.៩៧០.៩៩៣) |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពហិរញ្ញប្បទាន** | (១៣.៩២៧.២៦២) | (៥៧.១៩៩.២៦៥) | (៩.៦៨៧.៩២៨) | (៣៩.៤៦៨.៦១៩) |
| | | | | |
| កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ | (៤៧៦.០៩២) | (១.៩៥៥.៣១១) | (៨.៤៦៨.៩៩០) | (៣៤.៥០២.៦៦៦) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើម ការិយបរិច្ឆេទ | ៦៤.៧៥១.១៣៧ | ២៦៦.៥៨០.៤៣១ | ៦៥.៨២២.៩៣៤ | ២៦៨.១៦២.៦៣១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៣១៦.៦១៥ | - | ២.៥៨០.៩៣០ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុង ការិយបរិច្ឆេទ (កំណត់សម្គាល់ ១១)** | ៦៤.២៧៥.០៤៥ | ២៦៤.៩៤១.៧៣៥ | ៥៧.៣៥៣.៩៤៤ | ២៣៦.២៤០.៨៩៥ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ១៨ ដល់ទំព័រទី ២៦ គឺជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុចន្លោះពេលដោយឡែកសង្ខេបនេះ។

**ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក**

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុ ចន្លោះពេលរួម និងដោយឡែកសង្ខេប**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ និង៩ខែ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣**

## ១. ព័ត៌មានទូទៅ

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក (ហៅកាត់ថា "ធនាគារ") ដែលមានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលមានវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០១៥៧៩៤ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ ហើយបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីអនុវត្តប្រតិបត្តិការធនាគារដែលអនុវត្តចាប់ពី ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨។ ធនាគារចាប់ផ្តើមប្រតិបត្តិការជាផ្លូវការនៅ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨។

សកម្មភាពចម្បងរបស់ធនាគារគឺផ្តល់គ្រប់ផ្នែកទាំងអស់នៃអាជីវកម្មធនាគារ និងសេវាហិរញ្ញវត្ថុពាក់ព័ន្ធក្នុងព្រះរាជាណាចក្រកម្ពុជា។ គិតត្រឹម ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ធនាគារមានការិយាល័យកណ្តាល និង១៦ សាខា នៅក្នុងរាជធានីភ្នំពេញ និង ៧ សាខា នៅខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកណ្តាល និងខេត្តកំពត។

ក្រុមហ៊ុន ស្ពារ & ក្រេន ខេម (ហៅកាត់ថា "ក្រុមហ៊ុនបុត្រសម្ព័ន្ធ") គឺជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០១៣២៧៦ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥។ នៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២០ ក្រុមហ៊ុនបុត្រសម្ព័ន្ធបានទទួលការអនុម័តពីក្រសួងពាណិជ្ជកម្មក្នុងការប្តូរនាមករណ៍តាមផ្លូវច្បាប់ពី ក្រុមហ៊ុន ស្ពារ & ក្រេន ខេម ទៅជា ក្រុមហ៊ុន ជេ&អេ (ខេមបូឌា) អ៊ិនវេសម៉ិន ឯ.ក។ សកម្មភាពចម្បងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺទិញ លក់ ជួល និងប្រតិបត្តិការអចលវត្ថុដែលជាទ្រព្យផ្ទាល់ខ្លួន ឬជួល និងអភិវឌ្ឍគម្រោងសាងសង់។

ការិយាល័យចុះបញ្ជីរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន (ហៅកាត់ថា "សម្ព័ន្ធធនាគារ") ស្ថិតនៅអគារលេខ ២១៧ មហាវិថីព្រះនរោត្តម (ផ្លូវលេខ ៤១) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្នុងឆ្នាំ២០១៩ ធនាគារបានស្នើសុំផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា "ផ.ម.ក") និងនិយ័តករមូលបត្រកម្ពុជា (ហៅកាត់ថា "ន.ម.ក") ដើម្បីចុះបញ្ជីសញ្ញាបណ្ណសាជីវកម្មក្នុង ផ.ម.ក។ ធនាគារបានទទួលការអនុម័តចុងក្រោយពីន.ម.ក ដើម្បីចុះបញ្ជីសញ្ញាប័ណ្ណសាជីវកម្មរបស់ធនាគារនៅក្នុងផ.ម.ក នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ ហើយធនាគារបានចេញមូលបត្រជាលើកដំបូង នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០។

ព័ត៌មានហិរញ្ញវត្ថុចន្លោះពេលរួម និងដោយឡែកសង្ខេបត្រូវបានអនុម័តឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣។

ព័ត៌មានហិរញ្ញវត្ថុចន្លោះពេលរួម និងដោយឡែកសង្ខេបសម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ និង ៩ខែ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២៣ ត្រូវបានត្រួតពិនិត្យដោយពុំបានធ្វើសវនកម្មទេ។

## ២. មូលដ្ឋាននៃការរៀបចំព័ត៌មានហិរញ្ញវត្ថុ

ព័ត៌មានហិរញ្ញវត្ថុចន្លោះពេលរួម និងដោយឡែកសង្ខេបរបស់ធនាគារនេះត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIAS") លេខ៣៤ ស្តីពី "របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"។

## ២. មូលដ្ឋាននៃការរៀបចំព័ត៌មានហិរញ្ញវត្ថុ (ត)

ព័ត៌មានហិរញ្ញវត្ថុចន្លោះពេលរួម និងដោយឡែកសង្ខេបនេះមិនរួមបញ្ចូលនូវកំណត់សម្គាល់ទាំងអស់ ដែលត្រូវបានបង្ហាញជាទូទៅនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងដោយឡែកប្រចាំឆ្នាំដែលបានធ្វើសវនកម្មទេ។ ដូចនេះ របាយការណ៍នេះគួរត្រូវបានអានភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរួម និងដោយឡែកប្រចាំឆ្នាំ ដែលបានធ្វើសវនកម្ម សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដា របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRSs") និងសេចក្តីជូនដំណឹងជាសាធារណៈដែលធ្វើឡើងដោយសម្ព័ន្ធធនាគារ និងធនាគារក្នុងការិយបរិច្ឆេទចន្លោះពេល។

គោលនយោបាយគណនេយ្យដែលបានអនុវត្ត មានសង្គតិភាពជាមួយនឹងគោលនយោបាយគណនេយ្យក្នុងឆ្នាំហិរញ្ញវត្ថុមុន និងក្នុងការិយបរិច្ឆេទចន្លោះពេលមុនដែលពាក់ព័ន្ធ។

### ស្តង់ដាថ្មី និងស្តង់ដាដែលត្រូវបានវិសោធនកម្មដែលចូលជាធរមានក្នុងការិយបរិច្ឆេទបច្ចុប្បន្ន

មានស្តង់ដា ដែលបានធ្វើវិសោធនកម្មមួយចំនួន បានចូលជាធរមានសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្នដូចខាងក្រោម៖

| | |
|---|---|
| ការធ្វើវិសោធនកម្មទៅលើ CIAS ១ | *ចំណាត់ថ្នាក់នៃបំណុលរយៈពេលខ្លី ឬបំណុលរយៈពេលវែង* |
| ការធ្វើវិសោធនកម្មទៅលើ CIAS ១ | *បំណុលរយៈពេលវែងជាមួយលក្ខខណ្ឌនៃកិច្ចសន្យា* |
| ការធ្វើវិសោធនកម្មទៅលើ CIFRS ១៦ | *បំណុលភតិសន្យាក្នុងការលក់និងជួលបន្ត* |
| CIFRS ១៧ | *កិច្ចសន្យាធានារ៉ាប់រង* |
| ការធ្វើវិសោធនកម្មទៅលើ CIAS ៨ | *និយមន័យនៃការប៉ាន់ស្មានគណនេយ្យ* |
| ការធ្វើវិសោធនកម្មទៅលើ CIAS ១ និង CIFRSសេចក្តីថ្លែងការណ៍អនុវត្តន៍ទី២ | *ការបង្ហាញនៃគោលនយោបាយគណនេយ្យ* |

វិសោធនកម្មទៅលើស្តង់ដាទាំងនេះ មិនមានផលប៉ះពាល់ជាសារវន្តចំពោះសម្ព័ន្ធធនាគារ ឬធនាគារទេ។ ដូចនេះសម្ព័ន្ធធនាគារ ឬធនាគារមិនបានផ្លាស់ប្តូរគោលនយោបាយគណនេយ្យរបស់ខ្លួន ឬធ្វើនិយ័តកម្មត្រឡប់ក្រោយ ដោយសារការអនុវត្តស្តង់ដាទាំងនោះទេ។

### ស្តង់ដាCIFRS ថ្មី និងបានកែសម្រួលដែលបានចេញផ្សាយប៉ុន្តែមិនទាន់មានប្រសិទ្ធិភាព

ស្តង់ដាគណនេយ្យថ្មី វិសោធនកម្មទៅលើស្តង់ដាគណនេយ្យ និងការបកស្រាយជាក់លាក់ត្រូវបានបោះផ្សាយដែលមិនទាន់ត្រូវឱ្យអនុវត្តសម្រាប់ការិយបរិច្ឆេទថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២៣ និងមិនត្រូវបានអនុវត្តមុនដោយសម្ព័ន្ធធនាគារ និងធនាគារ។ ស្តង់ដា វិសោធនកម្ម ឬការបកស្រាយទាំងនេះមិនត្រូវបានរំពឹងថាមានផលប៉ះពាល់ជាសារវន្តទៅលើ សម្ព័ន្ធធនាគារ និងធនាគារនៅក្នុងការិយបរិច្ឆេទបច្ចុប្បន្ន ឬអនាគត និងប្រតិបត្តិការអនាគតដែលអាចប៉ាន់ស្មានបាននោះទេ។

### ការបង្ហាញជាប្រាក់រៀល

អនុលោមតាមច្បាប់ស្តីពី គណនេយ្យនិងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ការកត់ត្រាប្តូរពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀលត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយប្រើប្រាស់អត្រាចុងការិយបរិច្ឆេទ និងអត្រាមធ្យមសម្រាប់ការិយបរិច្ឆេទ ដូចដែលបានប្រកាសដោយធនាគារជាតិនៃកម្ពុជា។

## ២. មូលដ្ឋាននៃការរៀបចំព័ត៌មានហិរញ្ញវត្ថុ (ត)

**ការបង្ហាញជាប្រាក់រៀល (ត)**

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម និងដោយឡែកសង្ខេប និងលំហូរសាច់ប្រាក់រួម និងដោយឡែកសង្ខេបត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាមធ្យមប្រចាំការិយបរិច្ឆេទ។ ទ្រព្យសកម្ម និងបំណុលដែលបានដាក់បង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដោយឡែកសង្ខេបនីមួយៗ ត្រូវបានប្តូរដោយប្រើអត្រានាចុងការិយបរិច្ឆេទ។ លម្អៀងពីការប្តូរមូលធនភាគទុនិកត្រូវបានទទួលស្គាល់ផ្ទាល់ក្នុងមូលធន ហើយរាល់លម្អៀងពីការប្តូរផ្សេងៗទៀតទាំងអស់ ត្រូវបានទទួលស្គាល់ក្នុងលទ្ធផលលម្អិតផ្សេងៗ។

គិតត្រឹមចុងការិយបរិច្ឆេទ អត្រាមធ្យម និង អត្រាចុងការិយបរិច្ឆេទ គឺផ្អែកលើអត្រាប្តូរប្រាក់ដូច ខាងក្រោមក្នុង ១ដុល្លារអាមេរិក៖

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែ | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២២ | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ |
| អត្រាមធ្យម | ៤.១៣៣ រៀល | ៤.១០១ រៀល | ៤.១០៧ រៀល | ៤.០៧៤ រៀល |

| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ |
|---|---|---|
| អត្រាចុងការិយបរិច្ឆេទ | ៤.១២២ រៀល | ៤.១១៧ រៀល |

## ៣. ព្រឹត្តិការណ៍ និងប្រតិបត្តិការសំខាន់ៗ ក្នុងការិយបរិច្ឆេទរាយការណ៍នេះ

ព្រឹត្តិការណ៍សំខាន់ៗដែលបានកើតឡើង ក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

**ការធ្វើចំណាត់ថ្នាក់ និងសំវិធានធនតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជាចំពោះឥណទានដែលបានរៀបចំឡើងវិញ**

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជាបានចេញសារាចរណែនាំលេខ ធ៧-០២១-២៣១៤ ស.រ.ណ.ន ស្តីពីការតម្រូវចំពោះការធ្វើចំណាត់ថ្នាក់ និងសំវិធានធន ចំពោះឥណទានរៀបចំឡើងវិញ ក្នុងគោលបំណងកាត់បន្ថយហានិភ័យឥណទាន រក្សាស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រដល់ការស្តារសកម្មភាពផ្នែកសេដ្ឋកិច្ចឡើងវិញ។ យោងតាមសារាចរណែនាំនេះ គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវបានតម្រូវឱ្យកែប្រែការធ្វើចំណាត់ថ្នាក់ឥណទានរៀបចំឡើងវិញ ទៅតាមសារាចរណែនាំនេះ និងកត់ត្រាសំវិធានធនតាមច្បាប់ដោយផ្អែកទៅតាមចំណាត់ថ្នាក់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលអាចប៉ះពាល់ដល់ចំនួនដែលត្រូវផ្ទេររវាងចំណេញរក្សាទុក និងទុនបម្រុងតាមបទប្បញ្ញត្តិក្នុងការិយបរិច្ឆេទនៃឆ្នាំ ២០២២។

បន្ទាប់ពីចេញសារាចរណែនាំនេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាមួយ ដើម្បីបញ្ជាក់ថាគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់អាចអនុវត្តសារាចរខាងលើត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ឬក៏ ពន្យារពេលអនុវត្តរហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២។

## ៣. ព្រឹត្តិការណ៍ និងប្រតិបត្តិការសំខាន់ៗ ក្នុងការិយបរិច្ឆេទរាយការណ៍នេះ (ត)

ធនាគារបានជ្រើសរើសយកការអនុវត្តនៃសារាចរណែនាំ ចាប់ពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ និងបានឆ្លុះបញ្ចាំងពីផលប៉ះពាល់នៃចំនួនដែលត្រូវផ្ទេររវាងចំណេញរក្សាទុក និងទុនបម្រុងតាមបទប្បញ្ញត្តិ។

គិតត្រឹមចុងការិយបរិច្ឆេទ ធនាគារមានចំនួនកំណត់នៃឥណទានសកម្មដែលបានរៀបចំឡើងវិញដែលបណ្តាលមកពី ជំងឺកូវីដ១៩ ដូច្នេះសារាចរណែនាំនេះមិនមានផលប៉ះពាល់ជាសារវន្តដល់ធនាគារក្នុងការិយបរិច្ឆេទបច្ចុប្បន្នទេ។

### ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

នៅថ្ងៃទី ៩ ខែមករា ឆ្នាំ ២០២៣ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសលេខ ធ៧-០២៣-០០៥ ស្តីពីប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលតម្រូវឱ្យធនាគារតម្កល់ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចី មធ្យមប្រចាំថ្ងៃនៅធនាគារជាតិនៃកម្ពុជាស្របតាមកាលបរិច្ឆេទ និងអត្រាដូចខាងក្រោមៈ

- ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៣ ប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណក្រៅពីប្រាក់រៀលត្រូវមានកម្រិត ៩%។
- ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ តទៅ ប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណក្រៅពីប្រាក់រៀលត្រូវមានកម្រិត ១២,៥%។

ចំណែកប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណប្រាក់រៀល សម្ព័ន្ធធនាគារ និងធនាគារត្រូវរក្សាអត្រានៅកម្រិត ៧%ដដែល។

ធនាគារបានអនុវត្តយ៉ាងពេញលេញជាមួយនឹងការតម្រូវថ្មីនេះក្នុងអំឡុងការិយបរិច្ឆេទ។

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ

សម្ព័ន្ធធនាគារ និងធនាគារ ធ្វើការប៉ាន់ស្មាន និងការសន្មត ពាក់ព័ន្ធនាពេលអនាគត។ តាមនិយមន័យលទ្ធផលនៃការប៉ាន់ស្មានកម្រស្មើគ្នាជាមួយនឹងលទ្ធផលជាក់ស្តែងណាស់។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យសំខាន់ៗផ្សេងទៀត ដែលគណៈគ្រប់គ្រងបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់សម្ព័ន្ធធនាគារ និងធនាគារ និងប្រភពសំខាន់ៗក្នុងការប៉ាន់ស្មានភាពមិនច្បាស់លាស់ គឺដូចគ្នាជាមួយនឹងការអនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានធ្វើសវនកម្មរួច សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែរ។

## ៥. ព័ត៌មានតាមផ្នែក និងប្រាក់ចំណូល

សម្ព័ន្ធធនាគារ និងធនាគារមានផ្នែកដែលត្រូវរាយការណ៍តែមួយគត់គឺ ចំណូលសេវាធនាគារ។ ប្រធានដែលជាអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (ហៅកាត់ថា គណៈកម្មការប្រតិបត្តិ) ត្រួតពិនិត្យរបាយការណ៍គ្រប់គ្រងផ្ទៃក្នុង ដែលរាយការណ៍ អំពីផ្នែកនៃចំណូលសេវាធនាគារទាំងមូល ដើម្បីវាយតម្លៃអំពីលទ្ធផល និងបែងចែកធនធាន។ គណៈកម្មការប្រតិបត្តិក៏ត្រួតពិនិត្យអំពីប្រាក់ចំណេញមុនបង់ពន្ធ និងប្រាក់ចំណេញសុទ្ធទាំងមូលធៀបនឹងការិយបរិច្ឆេទមុនៗផងដែរ។

## ៦. ឥណទានផ្តល់ដល់អតិថិជន

### (ក) លម្អិតអំពីឥណទានផ្តល់ដល់អតិថិជន៖

| | ព័ត៌មានហិរញ្ញវត្ថុរួម | | | | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានផ្តល់ដល់អតិថិជនគិតតាមតម្លៃដករំលស់ | ៨៤៧.៣៣៦.២៥១ | ៣.៤៩២.៧២០.០២៧ | ៧៧៨.១៩៥.១០៧ | ៣.២០៣.៨២៩.២៥៦ | ៨៥៣.៦០៥.៩២៧ | ៣.៥១៨.៥៦៣.៦៣១ | ៧៨៤.៤៥៥.៥៧៦ | ៣.២២៩.៦០៣.៦០៦ |
| ដក៖ សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក | (៧.៧៣២.៥៧៨) | (៣១.៨៧៣.៦៨៧) | (៤.៩៤៧.០៤៤) | (២០.៣៦៦.៩៨០) | (៧.៧៣៨.៦៥៧) | (៣១.៨៩៨.៧៤៤) | (៤.៩៥០.៩២៣) | (២០.៣៨២.៩៥០) |
| **ឥណទានផ្តល់ដល់អតិថិជនសុទ្ធ** | ៨៣៩.៦០៣.៦៧៣ | ៣.៤៦០.៨៤៦.៣៤០ | ៧៧៣.២៤៨.០៦៣ | ៣.១៨៣.៤៦២.២៧៦ | ៨៤៥.៨៦៧.២៧០ | ៣.៤៨៦.៦៦៤.៨៨៧ | ៧៧៩.៥០៤.៦៥៣ | ៣.២០៩.២២០.៦៥៦ |

### (ខ) សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក

| | ព័ត៌មានហិរញ្ញវត្ថុរួម | | | | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ECL ១២ខែ (ដំណាក់កាលទី១) | ២.៤៥៤.១៩១ | ១០.១១៦.១៧៦ | ១.៦៨៦.៩២១ | ៦.៩៤៥.០៥៤ | ២.៤៦០.២៧០ | ១០.១៤១.២៣៣ | ១.៦៩០.៨០០ | ៦.៩៦១.០២៤ |
| ECL ពេញមួយអាយុកាល- ឥណទានមិនមានការថយចុះតម្លៃ (ដំណាក់កាលទី២) | ២៧៧.២០៣ | ១.១៤២.៦៣១ | ២៤៨.៥៧៦ | ១.០២៣.៣៨៧ | ២៧៧.២០៣ | ១.១៤២.៦៣១ | ២៤៨.៥៧៦ | ១.០២៣.៣៨៧ |
| ECL ពេញមួយអាយុកាល- ឥណទានមានការថយចុះតម្លៃ (ដំណាក់កាលទី៣) | ៥.០០១.១៨៤ | ២០.៦១៤.៨៨០ | ៣.០១១.៥៤៧ | ១២.៣៩៨.៥៣៩ | ៥.០០១.១៨៤ | ២០.៦១៤.៨៨០ | ៣.០១១.៥៤៧ | ១២.៣៩៨.៥៣៩ |
| | ៧.៧៣២.៥៧៨ | ៣១.៨៧៣.៦៨៧ | ៤.៩៤៧.០៤៤ | ២០.៣៦៦.៩៨០ | ៧.៧៣៨.៦៥៧ | ៣១.៨៩៨.៧៤៤ | ៤.៩៥០.៩២៣ | ២០.៣៨២.៩៥០ |

## ៧. ប្រាក់កម្ចី

| | ព័ត៌មានហិរញ្ញវត្ថុរួម | | | | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់កម្ចីតាមតម្លៃដករំលស់៖ | | | | | | | | |
| រយៈពេលខ្លី | ២.០៥៥.១៩៥ | ៨.៤៧១.៥១៣ | ២.៥៥៧.៨៣៨ | ១០.៥៣០.៦១៩ | ២.០៥៥.១៩៥ | ៨.៤៧១.៥១៣ | ២.៥៥៧.៨៣៨ | ១០.៥៣០.៦១៩ |
| រយៈពេលវែង | ១២.៥០៨.៤៣១ | ៥១.៥៥៩.៧៥៣ | ២.៣៩៣.៥២៨ | ៩.៨៥៤.១៥៥ | ១២.៥០៨.៤៣១ | ៥១.៥៥៩.៧៥៣ | ២.៣៩៣.៥២៨ | ៩.៨៥៤.១៥៥ |
| | ១៤.៥៦៣.៦២៦ | ៦០.០៣១.២៦៦ | ៤.៩៥១.៣៦៦ | ២០.៣៨៤.៧៧៤ | ១៤.៥៦៣.៦២៦ | ៦០.០៣១.២៦៦ | ៤.៩៥១.៣៦៦ | ២០.៣៨៤.៧៧៤ |

រាល់ប្រាក់កម្ចីពុំមានការធានា ហើយបានទទួលពីធនាគារក្នុងស្រុក និងក្រៅស្រុកដែលមានរយៈពេលចាប់ពី ១២ ខែ ដល់ ៨៤ ខែ (ឆ្នាំ២០២២៖ ១២ ខែ ដល់ ៨៤ ខែ) និងអត្រាការប្រាក់ចាប់ពី ២% ទៅ ៨,១៨៧% (២០២២៖ ២% ដល់ ៦,៥%)។

## ៨. មូលបត្របំណុលបានចេញផ្សាយ

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ មូលបត្របំណុលដែលមានប្រាក់ដើមចំនួន ៩.៨៦៣.១៨៩ ដុល្លារអាមេរិក (ប្រមាណជា ៣៩.៩៧០.៤៩៤.០០០រៀល) និងការប្រាក់ចំនួន ៣២០.៤៣៤ ដុល្លារអាមេរិក (ប្រមាណជា ១.២៩៩.០៤១.០០០ រៀល) ត្រូវបានដល់កាលកំណត់ និងទូទាត់ដោយធនាគារទៅឱ្យអ្នកកាន់កាប់សញ្ញាប័ណ្ណ។ មូលបត្របំណុលរបស់ធនាគារមួយទៀតដែលមានប្រាក់ដើមចំនួន ៩.៧០៦.៨៣២ ដុល្លារអាមេរិក (ប្រមាណជា ៣៩.៨៦១.៨៣៣.០០០ រៀល) និងការប្រាក់ចំនួន ៣១៧.៦៩០ ដុល្លារអាមេរិក (ប្រមាណជា ១.៣០៤.៦៧៨.០០០ រៀល) ត្រូវបានដល់កាលកំណត់ និងទូទាត់ដោយធនាគារទៅឱ្យអ្នកកាន់កាប់សញ្ញាប័ណ្ណ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣។ ចំនួននៅសល់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ គឺជាពន្ធកាត់ទុកទៅលើការប្រាក់មូលបត្របំណុលត្រូវបានកត់ត្រាជាបំណុលទៅកាន់អាជ្ញាធរពន្ធ។

## ៩. ចំណាយការប្រាក់

| | ព័ត៌មានហិរញ្ញវត្ថុរួម | | | | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | |
|---|---|---|---|---|---|---|---|---|
| | សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ | | | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ | | | |
| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បញ្ញើពីអតិថិជន | ៦.៥៦០.៣០៣ | ២៧.១១៣.៧៣៣ | ៤.១៥០.៨២០ | ១៧.០២២.៥១៣ | ៦.៥៦០.៣០៣ | ២៧.១១៣.៧៣៣ | ៤.១៥០.៨២០ | ១៧.០២២.៥១៣ |
| ប្រាក់បញ្ញើពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ១.៨៦១.៥៦០ | ៧.៦៩៣.៨២៧ | ១.៣៤៤.៦៤៨ | ៥.៥១៤.៤០១ | ១.៨៦១.៥៦០ | ៧.៦៩៣.៨២៧ | ១.៣៤៤.៦៤៨ | ៥.៥១៤.៤០១ |
| អនុបំណុល | ៣៤៧.៨៣៥ | ១.៤៣៧.៦០២ | ៣៤៧.៨៣៥ | ១.៤២៦.៤៧១ | ៣៤៧.៨៣៥ | ១.៤៣៧.៦០២ | ៣៤៧.៨៣៥ | ១.៤២៦.៤៧១ |
| ប្រាក់កម្ចី | ១៦៥.០៨០ | ៦៨២.២៧៦ | ៣៤០.២០៣ | ១.៣៩៥.១៧៣ | ១៦៥.០៨០ | ៦៨២.២៧៦ | ៣៤០.២០៣ | ១.៣៩៥.១៧៣ |
| មូលបត្របំណុល | ២៩០.២៣៩ | ១.១៩៩.៥៥៨ | ៣៣.៤០៤ | ១៣៦.៩៩០ | ២៦៣.១៥៨ | ១.០៨៧.៦៣២ | ៥០.៣៣៣ | ២០៦.៤១៦ |
| បំណុលភតិសន្យា | ១០៦.៤៣៨ | ៤៣៩.៩០៨ | ១០៤.៨៥៨ | ៤៣០.០២៣ | ១៨៤.០៤៦ | ៧៦០.៦៦២ | ១៨៧.៦០៤ | ៧៦៩.៣៦៤ |
| | ៩.៣៣១.៤៥៥ | ៣៨.៥៦៦.៩០៤ | ៦.៣២១.៧៦៨ | ២៥.៩២៥.៥៧១ | ៩.៣៨១.៩៨២ | ៣៨.៧៧៥.៧៣២ | ៦.៤២១.៤៤៣ | ២៦.៣៣៤.៣៣៨ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុ ចន្លោះពេលរួម និងដោយឡែកសង្ខេប**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ និង៩ខែ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣**

## ៩. ចំណាយការប្រាក់ (ត)

| | ព័ត៌មានហិរញ្ញវត្ថុរួម សម្រាប់ដំណាច់ការិយបរិច្ឆេទ ៩ខែ | | | | ព័ត៌មានហិរញ្ញវត្ថុដោយឡែក សម្រាប់ដំណាច់ការិយបរិច្ឆេទ ៩ខែ | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បញ្ញើពីអតិថិជន | ១៨.០០១.៤០៩ | ៧៣.៩៣១.៧៨៦ | ១២.៦៨៣.៦៨៣ | ៥១.៦៧៣.៣២៥ | ១៨.០០១.៤០៩ | ៧៣.៩៣១.៧៨៦ | ១២.៦៨៣.៦៨៣ | ៥១.៦៧៣.៣២៥ |
| ប្រាក់បញ្ញើពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ៥.៦៧០.៦៨០ | ២៣.២៨៩.៤៨៣ | ២.៩៤៣.០៧១ | ១១.៩៩០.០៧១ | ៥.៦៧០.៦៨០ | ២៣.២៨៩.៤៨៣ | ២.៩៤៣.០៧១ | ១១.៩៩០.០៧១ |
| អនុបំណុល | ១.០៣២.១៦៤ | ៤.២៣៩.០៩៨ | ១.០៣២.១៦៤ | ៤.២០៥.០៣៦ | ១.០៣២.១៦៤ | ៤.២៣៩.០៩៨ | ១.០៣២.១៦៤ | ៤.២០៥.០៣៦ |
| មូលបត្របំណុល | ៦៧៦.០៦៧ | ២.៧៧៦.៦០៧ | ១.០១៤.៧៥៨ | ៤.១៣៤.១២៤ | ៦៧៦.០៦៧ | ២.៧៧៦.៦០៧ | ១.០១៤.៧៥៨ | ៤.១៣៤.១២៤ |
| ប្រាក់កម្ចី | ៦៤៨.១៣៩ | ២.៦៦១.៩០៧ | ១៤១.៨២៥ | ៥៧៧.៧៩៥ | ៦៤០.៣៤៩ | ២.៦២៩.៩១៣ | ១៧៥.៤៤៩ | ៧១៤.៧៧៩ |
| បំណុលភតិសន្យា | ៣២៤.៩៣៤ | ១.៣៣៤.៥០៤ | ៣០០.៧៣៧ | ១.២២៥.២០៣ | ៥៤៤.៥១១ | ២.២៣៦.៣០៧ | ៥៥២.៣៧៥ | ២.២៥០.៣៧៦ |
| | ២៦.៣៥៣.៣៩៣ | ១០៨.២៣៣.៣៨៥ | ១៨.១១៦.២៣៨ | ៧៣.៨០៥.៥៥៤ | ២៦.៥៦៥.១៨០ | ១០៩.១០៣.១៩៤ | ១៨.៤០១.៥០០ | ៧៤.៩៦៧.៧១១ |

## ១០. ភាគលាភ

នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ ក្រុមប្រឹក្សាភិបាលបានចេញសេចក្តីសម្រេចមួយដើម្បីអនុម័តទៅលើការបែងចែកភាគលាភនូវទឹកប្រាក់ចំនួន ២.០០០.០០០ ដុល្លារអាមេរិក (ប្រមាណជា ៨.២១៤.០០០.០០០រៀល)។ ភាគលាភនេះត្រូវបានអនុញ្ញាតិ្តបន្ទាប់មកទៀតដោយធនាគារជាតិនៃកម្ពុជានាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ និងត្រូវបានទូទាត់ពេញលេញនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣។

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុ ចន្លោះពេលរួម និងដោយឡែកសង្ខេប**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ និង៩ខែ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣**

## ១១. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សម្រាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

| | ព័ត៌មានហិរញ្ញវត្ថុរួម | | | | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សាច់ប្រាក់ក្នុងដៃ | ៣១.៩៨៤.៨៣៣ | ១៣១.៨៣៩.៨៣៣ | ៣៣.៣៧៦.៩៧០ | ១៣៧.៤៧៩.៧៣៩ | ៣១.៩៨៤.៨៣៣ | ១៣១.៨៣៩.៨៣៣ | ៣៣.៣៧៦.៩៧០ | ១៣៧.៤៧៩.៧៣៩ |
| *សមតុល្យនៅធនាគារជាតិនៃកម្ពុជា* | | | | | | | | |
| គណនីសម្រាប់ទូទាត់ | ៣.៣៦០.៤៨៧ | ១៣.៨៥១.៩២៧ | ១.២១៥.៥៨៧ | ៥.០០៧.០០៣ | ៣.៣៦០.៤៨៧ | ១៣.៨៥១.៩២៧ | ១.២១៥.៥៨៧ | ៥.០០៧.០០៣ |
| គណនីចរន្ត | ១៤.៧៥៩.៤៥៥ | ៦០.៨៣៨.៤៧៤ | ១៤.៦១១.១៣៤ | ៦០.១៨៣.២៦១ | ១៤.៧៥៩.៤៥៥ | ៦០.៨៣៨.៤៧៤ | ១៤.៦១១.១៣៤ | ៦០.១៨៣.២៦១ |
| មូលបត្រអាចជួញដូរ | ៣.២៨៤.០០០ | ១៣.៥៣៦.៦៤៨ | - | - | ៣.២៨៤.០០០ | ១៣.៥៣៦.៦៤៨ | - | - |
| *សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ* | | | | | | | | |
| គណនីសន្សំ | ៥.៥៣៨.០៦០ | ២២.៨២៧.៨៨៣ | ២.៧៩៣.២៩៦ | ១១.៥០៥.៥៨៦ | ៥.៥៣៨.០៦០ | ២២.៨២៧.៨៨៣ | ២.៧៩៣.២៩៦ | ១១.៥០៥.៥៨៦ |
| គណនីចរន្ត | ២.៣៤៨.៦១០ | ៩.៦៨០.៩៧០ | ២.៣៥៦.៩៥៧ | ៩.៧០៨.៣០៦ | ២.៣៤៨.៦១០ | ៩.៦៨០.៩៧០ | ២.៣៥៦.៩៥៧ | ៩.៧០៨.៣០៦ |
| គណនីមានកាលកំណត់ដើមមិនលើសពីរយៈពេល៣ខែ | ៣.០០០.០០០ | ១២.៣៦៦.០០០ | ៣.០០០.០០០ | ១២.៣៥៧.០០០ | ៣.០០០.០០០ | ១២.៣៦៦.០០០ | ៣.០០០.០០០ | ១២.៣៥៧.០០០ |
| | ៦៤.២៧៥.០៤៥ | ២៦៤.៩៤១.៧៣៥ | ៥៧.៣៥៣.៩៤៤ | ២៣៦.២៤០.៨៩៥ | ៦៤.២៧៥.០៤៥ | ២៦៤.៩៤១.៧៣៥ | ៥៧.៣៥៣.៩៤៤ | ២៣៦.២៤០.៨៩៥ |